00775755

E165

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 06 / 02 / 2012
ម៉ោង (Time/Heure) : 13:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង ០០២

ការិយាល័យរដ្ឋបាល

ផ្នែកគ្រប់គ្រងតុលាការ

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង;
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** ពេលវេលាដែលអង្គជំនុំជម្រះមិនធ្វើសវនាការក្នុងឆ្នាំ ២០១២

ក្នុងន័យជួយសម្រួលដល់ការរៀបចំផែនការការងារ អង្គជំនុំជម្រះសាលាដំបូងសូមជូនដំណឹងទៅភាគីអំពីពេលវេលាដែលអង្គជំនុំជម្រះមិនធ្វើសវនាការក្នុងឆ្នាំ ២០១២ ដែលមានដូចខាងក្រោមនេះ៖

ថ្ងៃ សុក្រ ទី ១៧ ខែ កុម្ភៈ ដល់ថ្ងៃ សុក្រ ទី ០៩ ខែ មីនា ឆ្នាំ ២០១២ (ការបញ្ចប់សវនាការវគ្គដំបូងក្នុងឆ្នាំ ២០១២)

ថ្ងៃ សុក្រ ទី ១៣ ដល់ថ្ងៃ ច័ន្ទ ទី ១៦ ខែ មេសា ឆ្នាំ ២០១២ (ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ)

ថ្ងៃ ច័ន្ទ ទី ១៤ ដល់ថ្ងៃ អង្គារ ទី ១៥ ខែ ឧសភា ឆ្នាំ ២០១២ (រាប់បញ្ចូលថ្ងៃបុណ្យជាតិ)

ថ្ងៃ ច័ន្ទ ទី ២៥ ខែ មិថុនា ដល់ថ្ងៃ សុក្រ ទី ១៣ ខែ កក្កដា ឆ្នាំ ២០១២ (ថ្ងៃឈប់សម្រាករដូវក្តៅនៅអឺរ៉ុប)

00775756

E165

ថ្ងៃ ច័ន្ទ ទី ១៥ ដល់ថ្ងៃ អង្គារ ទី ១៦ ខែ តុលា ឆ្នាំ ២០១២ (ពិធីបុណ្យភ្ជុំបិណ្ឌ)

ថ្ងៃ ច័ន្ទ ទី ២៩ ខែ តុលា ដល់ថ្ងៃ សុក្រ ទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (រាប់បញ្ចូលថ្ងៃបុណ្យជាតិ)

ថ្ងៃ ច័ន្ទ ទី ២៦ ដល់ថ្ងៃ សុក្រ ទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក)

ថ្ងៃ ច័ន្ទ ទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ ដល់ថ្ងៃ សុក្រ ទី ០៤ ខែ មករា ឆ្នាំ ២០១៣ (បុណ្យណូអែល/បុណ្យចូលឆ្នាំសកល)

នៅក្នុងអំឡុងពេលនៃថ្ងៃផ្អាកមិនធ្វើសវនាការដូចបញ្ជាក់ខាងលើ ផ្នែកគ្រប់គ្រងតុលាការនឹងពុំទទួលឯកសារណាមួយសម្រាប់ដាក់ចូលក្នុងសំណុំរឿង ០០២ ឡើយ លើកលែងតែពេលវេលាចាប់ពីថ្ងៃទី ១៧ ខែ កុម្ភៈ ដល់ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១២ និងអាចមានការលើកលែងផងដែរចាប់ពីថ្ងៃទី ២៥ ខែ មិថុនា ដល់ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១២។ ប៉ុន្តែពេលវេលាកំណត់សម្រាប់ការដាក់ឯកសារ ត្រូវគិតក្នុងអំឡុងពេលថ្ងៃផ្អាកមិនធ្វើសវនាការខាងលើ។ ក្នុងករណីដែលពេលវេលាកំណត់ត្រូវនឹងថ្ងៃណាមួយក្នុងអំឡុងថ្ងៃខាងលើ កាលបរិច្ឆេទសម្រាប់ការដាក់ឯកសារគឺនៅថ្ងៃចូលធ្វើការដំបូងក្រោយថ្ងៃផ្អាកសវនាការ។ អង្គជំនុំជម្រះនឹងជម្រាបជូនដំណឹងដល់ភាគីនានាក្នុងរយៈពេលសមស្របខាងមុខនេះថាតើចាប់ពីថ្ងៃទី ២៥ ខែ មិថុនា ដល់ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១២ ផ្នែកគ្រប់គ្រងតុលាការនឹងទទួល ឬមិនទទួលឯកសារដើម្បីដាក់ចូលក្នុងសំណុំរឿង។

ថ្វីត្បិតរយៈពេលនៃថ្ងៃផ្អាកសវនាការខាងលើភាគច្រើន ត្រូវនឹងថ្ងៃឈប់សម្រាកជាសាធារណៈរបស់ជាតិ និងអន្តរជាតិក្តី ក៏អង្គជំនុំជម្រះនឹងពុំធ្វើសវនាការនៅថ្ងៃឈប់សម្រាកជាសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប មួយចំនួនផ្សេងទៀត។ នាពេលកន្លងមក កាលបរិច្ឆេទនៃថ្ងៃឈប់សម្រាកបន្ថែមជាសាធារណៈរបស់ អ.វ.ត.ក នេះ ត្រូវបានការិយាល័យរដ្ឋបាលផ្ញើទៅភាគីនៅក្នុងសារាចររបស់ខ្លួនដែលមានចំណងជើងថា “ថ្ងៃបុណ្យឈប់សម្រាកជាផ្លូវការសម្រាប់ឆ្នាំ ២០១២” ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១១ ដែលភ្ជាប់មកជាមួយសម្រាប់ជាឯកសារយោង។

អង្គជំនុំជម្រះសូមបញ្ជាក់ថាថ្ងៃផ្អាកមិនធ្វើសវនាការ ពុំមែនជាថ្ងៃឈប់សម្រាកឡើយ។ ថ្ងៃទាំងនោះគ្រាន់តែជាថ្ងៃដែលអង្គជំនុំជម្រះមិនធ្វើសវនាការប៉ុណ្ណោះ។ ក្នុងអំឡុងពេលនោះ អង្គជំនុំជម្រះនឹងធ្វើ

ការងារពាក់ព័ន្ធនឹងសេចក្តីសម្រេចនានា និងការរៀបចំផែនការសម្រាប់សវនាការដំណាក់កាលបន្តបន្ទាប់ទៀត។ រយៈពេលដែលអង្គជំនុំជម្រះមិនធ្វើសវនាការ ក៏មានសារៈសំខាន់ផងដែរដោយទុកឱកាសឲ្យមានការកោះប្រជុំគណៈកម្មាធិការរដ្ឋបាលតុលាការ គណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង និងកិច្ចប្រជុំពេញអង្គក្នុងករណីចាំបាច់។